# កម្មវិធីនៃ
# ពិធីសម្ពោធកម្មវិធីរបស់ "គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ "
# ថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០០៦ នៅសណ្ឋាគារសាន់វេ

១៤:០០ - ១៤:១០ ការចុះឈ្មោះ

១៤:១០ - ១៤:១៥ ការស្វាគមន៏ និង គោរពទង់ជាតិ

១៤:១៥- ១៤:២០ មតិស្វាគមន៏របស់លោកស្រី **ម៉ុក ណារណ្ណា** នាយិកាអង្គការចំរើនស្ត្រី

១៤:២០ - ១៤:៣៥ សុន្ទរកថាបើកពិធីសម្ពោធកម្មវិធី ដោយ**លោកជំទាវឃឹម ចំរើន** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី

១៤:៣៥ - ១៥:០៥ ការណែនាំអំពីកម្មវិធី របស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យ នយោបាយ ដោយ**លោកស្រី ធីដា ឃឹះ**

លេខាធិការរបស់គណៈកម្មាធិការ និង ជានាយិការអង្គការសីលការ

១៥:០៥ - ១៥:២០ សំរាក

១៥:២០ - ១៦:០៥ ការសំដែងចំណាប់អារម្មណ៍ ចំពោះកម្មវិធីរបស់គណៈកម្មាធិការដោយ

- **លោកជំទាវ ហូ ណាុន**
  សមាជិកគណៈកម្មាធិការកណ្តាលនៃគណបក្សប្រជាជនកម្ពុជា
  និងជាប្រធានគណៈកម្មាធិការទី៨ នៃរដ្ឋសភា
- **ឯកឧត្តម សឿង ឫទ្ធីស័ក្តិ**
  អនុប្រធាននាយកដ្ឋានកិច្ចការមូលដ្ឋាននៃគណបក្សហ៊្វុនស៊ិនប៊ិច
- **លោកស្រី មូ សុខហួរ**
  សមាជិកគណៈកម្មាការនាយកនៃគណបក្សសមរង្ស៊ី

១៦:០៥ - ១៦:២០ ចំណាប់អារម្មណ៏របស់ **ឯកឧត្តម ខ៉ាន់ ចំរើន** អគ្គនាយករងរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ

១៦:២០ - ១៦:៥០ កម្មវិធីសំនួរ - ចំលើយ

១៦:៥០ - ១៧:០០ ពិធីកាត់ខ្សែបូរសម្ពោធកម្មវិធី

១៧:០០ - ១៧:១០ ពិធីថតរូប

១៧:១០ - ១៧:១៥ បិទកម្មវិធី

១៧:១៥ - ១៧:៣០ សន្និសិទ្ធិកាសែត

# កំណត់ហេតុ
# ស្តីពី
# ការប្រារព្ធពិធីសម្ពោធកម្មវិធីរបស់
# គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ

ថ្ងៃទី ៩ ខែ តុលា ឆ្នាំ ២០០៦ វេលាម៉ោង ២.៣០នាទី ល្ងាច នៅសណ្ឋាគារ សាន់វេ បានប្រារព្ធពិធីសម្ពោធកម្មវិធី របស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ គណៈគណៈអធិបតីរួមមាន :

១- លោកជំទាវ ហូ ណូន សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា

២- លោក ជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការក្រសួងកិច្ចការនារី

៣- ឯកឧត្តម ង៉ាន់ ចំរើន អគ្គនាយករង នៃអគ្គនាយកដ្ឋានក្រសួងមហាផ្ទៃ

៤- ឯកឧត្តម សឿង ឫទ្ធីស័ក្តិ អនុប្រធាននាយកដ្ឋានកិច្ចការមូលដ្ឋាននៃគណៈបក្សហ៊្វុនស៊ិនប៉ិច

៥- លោកជំទាវ មួរ សុខហួរ សមាជិកគណៈកម្មាធិការនាយកនៃគណបក្សសមរង្ស៊ី

៦- លោកស្រី ធីតា ឃីះ លេខាធិការនៃគណៈកម្មាធិការ និង ជានាយិកាអង្គការសីលកា

អញ្ជើញចូលរួមជាភ្ញៀវកិត្តិយសមានចំនួន ១១០ នាក់ រួមមាន :

- តំណាងសមាជិករដ្ឋាភិបាល
- តំណាងគណបក្សនយោបាយធំៗ ៣ គឺ គណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និង គណបក្សសមរង្ស៊ី
- តំណាងអង្គការជាតិ និង អន្តរជាតិ
- សមាជិកគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ
- តំណាងអង្គការជាម្ចាស់ជំនួយ
- តំណាងសារពតិមាន អ្នកកាសែត វិទ្យុ និង ទូរទស្សន៍

ជាកិច្ចចាប់ផ្តើមលោកស្រី ប៉ុក ណណ្តា សមាជិកគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និង ជានាយិកា

អង្គការចំរើនស្ត្រីបានឡើងមានមតិស្វាគមន៍ចំពោះវត្តមានគណៈអធិបតីនិងភ្ញៀវកិត្តិយសទាំងអស់ដែលបានមកចូលរួមក្នុងពិធីសម្ពោធកម្មវិធីរបស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយជាផ្លូវការ ។ សមាជិកគណៈកម្មាធិការលើកស្ទួយ ស្ត្រីក្នុងវិស័យនយោបាយបានចាប់បដិសន្ធិឡើងនៅឆ្នាំ ២០០៥ ជាអង្គការសមាគមមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៧ រួមមាន អង្គការសីលកា អង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា អង្គការខុមប្រែល អង្គការនិកហ្វិក អង្គការចំរើនស្ត្រី សមាគមនារីកម្ពុជាដើម្បីសន្តិភាព និង អភិវឌ្ឍន៍ និង វិទ្យាស្ថានស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ។ ក្នុងនោះ ដែរលោកស្រី ក៏បានជំរាបជូនអ្នកចូលរួមអំពីទស្សនៈ វិស័យថា

សង្គមកម្ពុជាស្ត្រីនិង បុរសមានសិទ្ធស្មើគ្នាក្នុងការទទួលបានឳកាស និង ផលប្រយោជន៍ពីសង្គម ។ ដើម្បីសំរេចដល់ទស្សនៈវិស័យខាងលើនេះ គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយត្រូវបានកំណត់បេសកកម្មដូចខាងក្រោម :

- លើកស្ទួយស្ត្រី និង បុរស អោយមានការចូលរួមស្មើគ្នា ក្នុងការសំរេចចិត្ត និង ឈរឈ្មោះជាតំណាងក្នុងមុខងារ សាធារណៈ ។
- សហការគ្នាអភិវឌ្ឍន៍ និង អនុវត្តការងារ ដោយសកម្មដើម្បីជួយជ្រោមជ្រែងបង្កើនសមាមាត្រស្ត្រីក្នុងការចូលរួម ការងារសង្គម និង នយោបាយ ។

ជាកិច្ចបន្តលោកជំទាវ ឃឹម ចំរើន បានឡើងមានចំណាប់អារម្មណ៍ កោតសរសើរយ៉ាងក្រៃលែង ចំពោះគំនិតផ្តួចផ្តើមរបស់លោក លោកស្រី ដែលបានបង្កើតគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយនេះឡើង ដើម្បីធ្វើសកម្មភាព ជំរុញស្ត្រីអោយចូលរួមអោយបានច្រើនក្នុងវិស័យនយោបាយ ។ រាជរដ្ឋាភិបានបើកទូលាយដោយមិនកំណត់កូតាទេ ព្រមទាំង បានបង្កើនស្ត្រីចូលរួមអោយបានច្រើនទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ព្រោះថាគោលការណ៏ របស់រាជរដ្ឋាភិបាល បានថែងថា " **ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិយើង** " និង សូមអោយគណបក្ស នយោបាយនិមួយៗ យកចិត្តទុកដាក់ចំពោះស្ត្រី ប្រសិនបើក្រុមប្រឹក្សាឃុំ-សង្កាត់ណាគ្មានស្ត្រី គឺសំណូមពរសុំអោយរើសស្ត្រីជាជំនួយការ ។ នៅមុនការបោះឆ្នោតឆ្នាំ២០០៣ ក្រសួងមហាផ្ទៃបានចេញសេចក្តីណែនាំថា ក្នុងចំណោមមេភូមិ អនុប្រធាន ជំនួយការត្រូវតែ មាន ស្ត្រីយ៉ាង តិច ១នាក់ ជាលទ្ធផលបណ្តោះអាសន្នមានស្ត្រី ៣៩៣ នាក់ ជាប់ជាប្រធានភូមិ ស្មើនឹង ២,៨៦ % ។ នៅភ្នំពេញ មានខណ្ឌទាំងអស់ ៧ និង ៧៦ សង្កាត់ មាន៦៨៥ ភូមិ មានអ្នកដឹកនាំស្ត្រីតែ ៩៥ ភូមិទេ ចំណែក ៥៣២ ភូមិទៀតមិនមានស្ត្រីជាថ្នាក់ដឹកនាំទេ ។ នៅបញ្ចប់លោកជំទាវបានប្រកាសបើកកម្មវិធីរបស់គណៈកម្មាធិការលើកស្ទួយស្ត្រី ក្នុងវិស័យនយោបាយចាប់ពីពេលនេះតទៅ ។

បន្ទាប់មកលោកស្រី ធីតា ឃឹះ បានឡើងបង្ហាញពីកសម្មភាពរបស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោ- បាយក្នុងរយៈពេលកន្លងមក ។ យុទ្ធសាស្ត្ររបស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងនយោបាយគឺ អនុវត្តសកម្មភាពតាមរយៈ ប្រព័ន្ធផ្សព្វផ្សាយក្នុងវេទិកាសាធារណៈ វគ្គបណ្តុះបណ្តាលដល់ស្ត្រី សិល្បៈអប់រំ ការបញ្ចុះបញ្ចូល ការតស៊ូមតិ និងការផ្សព្វផ្សាយឯកសារអប់រំ ដើម្បីលើកកំពស់ការយល់ដឹងជាសាធារណៈ និង ស្វែងរកការគាំទ្រពីប្រជាពលរដ្ឋ និង គណបក្សនយោបាយ ហើយសកម្មភាពនិមួយៗបានប្រគល់អោយអង្គការជាសមាជិកអនុវត្តដូចជា អង្គការវិទ្យាស្ថានស្រាវជ្រាវដើម្បី អភិវឌ្ឍន៏កម្ពុជា (CDRI )ធ្វើទៅលើការស្ទង់មតិដើម្បីស្វែងរកអោយឃើញចំពោះភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅមូលដ្ឋាន ។ ដោយអង្គការយេនឌ័រ និង អភិវឌ្ឍន៍ដើម្បីកម្ពុជា ( GAD/C ) រៀបចំវេទិកាសាធារណៈ បច្ចុប្បន្នបានរៀបចំ នៅខេត្តចំនួន ២ ហើយ

គឺខេត្តកំពង់ធំ និងខេត្តកំពត។ អង្គការចំរើនស្ត្រីរៀបចំហ្វឹកហ្វឺនជាវគ្គសិក្សានៅ ៨ខេត្ត ដោយមានគណបក្សនយោបាយ ចំនួន ៧ចូលរួម ។ អង្គការនិកហ្វិករៀបចំផ្សព្វផ្សាយឯកសារតាមវិទ្យុ ទូរទស្សន៍ សិល្បៈអប់រំ ដល់ខេត្ត-ក្រុង ។ គណៈកម្មាធិការបានធ្វើសកម្មភាពជាច្រើនដូចជា : ចូលរួមតាំងពិពណ៌ដែលមានអង្គការចំនួន១២ ចូលរួម, ផ្សព្វផ្សាយនៅតាម សកលវិទ្យាល័យ, រៀបចំវេទិកាសាធារណៈ, បោះពុម្ពឯកសារសំរាប់ផ្សព្វផ្សាយ យើងមានពាក្យស្លោកជាច្រើនដូចជា ស្ត្រីជាប់ ឆ្នោត បញ្ហាចោទត្រូវបានដោះស្រាយ ។ល។

## កម្មវិធីចំណាប់អារម្មណ៍របស់វាគ្មិន

១- លោកជំទាវ ហូ ណូន តំណាងគណបក្សប្រជាជនកម្ពុជា

២- លោក សឿងឫទ្ធីសត្ត តំណាងគណបក្សហ៊្វុន ស៊ីនប៉ិច

៣- លោក លោកជំទាវ មូរ សុខហួរ តំណាង គណបក្សសមរង្ស៊ី

៤- លោក ង៉ាន់ ចំរើន តំណាងមកពីក្រសួងមហាផ្ទៃ

**១- មតិលោកជំទាវ ហូ ណូន សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា**

ក្នុងនាមគណបក្សប្រជាជនកម្ពុជា សូមអបអរសាទរចំពោះការបង្កើតឡើងនូវគណៈកម្មាធិការលើកស្ទួយស្ត្រី ក្នុងវិស័យនយោបាយ នេះជាសក្ខីភាពបញ្ជាក់ពីការគាំទ្រ និង ការយកចិត្តទុកដាក់ក្នុងការធ្វើអោយប្រសើរឡើងនូវស្ថានភាពរបស់ស្ត្រី ។ ក្នុងឱកាសនោះដែរលោកជំទាវក៏បានលើកឡើងអំពីប្រវិត្តចលនារបស់ស្ត្រីនៃគណបក្សប្រជាជនកម្ពុជា ដែលមាន ដើមកំណើតតាំងពីពេលក៏កើតឡើងនូវគណបក្សប្រជាជនកម្ពុជា ពេលនោះចលនាស្ត្រីក៏កើតទន្ទឹមគ្នាដែរដើម្បីបំរើអោយផល ប្រយោជន៍របស់ប្រជាជន ។

នៅក្នុងរបបប្រល័យពូជសាសន៍ ប៉ុល ពត ពួកគេក៏បានប្រើប្រាស់អង្គការចាត់តាំងជាស្ត្រីដើម្បីបំរើនយោបាយប្រល័យ ពូជសាសន៍របស់គេតែប៉ុណ្ណោះ ។ បន្ទាប់ពីរបបប្រល័យពូជសាសន៍ ត្រូវបានផ្តួលរំលំរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាបាន ដឹកនាំប្រទេសក្រោមការដឹកនាំរបស់គណបក្សប្រជាជនបដិវត្តកម្ពុជា ពេលនោះស្ត្រីដែលនៅសល់ភាគច្រើនបានរួមគ្នាកសាង និងស្តារប្រទេសជាតិតាំងពីបាតដៃទទេ ។ ពេលនោះចលនាស្ត្រីរបស់គណបក្សដែលមានឈ្មោះថា សមាគមនារីសង្គ្រោះជាតិដែលជាស្ថាបនិកដ៏សំខាន់ក្នុងការរួមចំណែក អនុវត្តគោលនយោបាយរបស់គណបក្ស ការពារនិងកសាងប្រទេស ។

ក្រោយកិច្ចព្រមព្រៀងនាទីក្រុងប៉ារីសឆ្នាំ២០០៣ រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេច ហ៊ុន សែន ជាប្រមុខ បានចាត់ទុកបញ្ហាស្ត្រី និងយេនឌ័រជាអាទិភាព នៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ដូចជាផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ៥ឆ្នាំ លើកទី ២ (២០០១-២០០៥ ) និងលើកទី៣ (២០០៦-២០១០ ) យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (ឆ្នាំ ២០០៣) គោលដៅអភិវឌ្ឍន៍សហសវត្សកម្ពុជា (ឆ្នាំ២០០៣) គោលនយោបាយជាតិប្រជាជនឆ្នាំ ២០០៣ និង យុទ្ធសាស្ត្រចតុកោណ
(ឆ្នាំ ២០០៤) ដោយបានចាត់ទុកស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមកិច្ច ហើយធានាសិទ្ធិរបស់ស្ត្រីចូលរួមយ៉ាងសកម្ម និង ស្មើភាពក្នុងការកសាងជាតិ ។

ទស្សនៈវិស័យរបស់គណបក្សប្រជាជនកម្ពុជា

គឺបង្កើនសមាមាត្រនៃការចូលរួមរបស់ស្ត្រីអោយបានច្រើនជាអតិបរមា

គោលនយោបាយចំពោះស្ត្រីរបស់គណបក្សប្រជាជនកម្ពុជា គឺ

១- ជំរុញការអនុវត្តយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ កសាងសមត្ថភាពស្ត្រីលើគ្រប់ផ្នែក ពិសេសវិស័យនយោបាយ ។

២- ជំរុញការកសាងសមត្ថភាពស្ត្រី និង លើកទឹកចិត្តដល់ស្ត្រីអោយចូលរួមកាន់តែច្រើនទៅក្នុងសកម្មភាពសង្គម ជា ពិសេសការរៀបចំផែនការ និង ការធ្វើសេចក្តីសំរេចចិត្តនៅគ្រប់កំរិតទាំងអស់ ថ្នាក់ជាតិ ថ្នាក់ខេត្ត និង ថ្នាក់ មូលដ្ឋាន ។

៣- កែប្រែឥរិយាបទសង្គមដែលរើសអើងចំពោះស្ត្រីអោយយល់ច្បាស់អំពីតួនាទីរបស់ស្ត្រី និង មានការគាំទ្រជាសាធារណៈ ព្រមទាំងមានការធានានូវសិទ្ធិសំរាប់ស្ត្រី ដើម្បីអោយស្ត្រីមានលិទ្ធភាពគ្រប់គ្រាន់ចូលរួមយ៉ាងសកម្ម និងស្មើភាពនៅក្នុងដំណើរការកសាងប្រទេស ។

៤- ស្ត្រីទាំងអស់ត្រូវបានទទួលការគាំពារខាងផ្លូវច្បាប់ រួចផុតពីអំពើហឹង្សា នឹងការជួញដូរគ្រប់ប្រភេទ ទទួលបាន ការថែរទាំសុខភាព ការអប់រំ និងការបណ្តុះបណ្តាលមុខជំនាញ នៅគ្រប់កំរិតទាំងអស់ ។

សូមអំពាវនាវដល់អង្គការជាតិ និង អន្តរជាតិទាំងអស់ ភ្នាក់ងារអង្គការសហប្រជាជាតិ សូមបន្តជួយដល់សកម្មភាព

របស់ស្ត្រី ។ ជាមួយនេះខ្ញុំសូមអំពាវនាវដល់គ្រប់និន្នាការទាំងអស់ បន្តយកចិត្តទុកដាក់បង្កើនសមាមាត្រនៃការចូលរួមរបស់ ស្ត្រីអោយបានជាអតិបរមា ជាពិសេសនៅក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ នាពេលខាងមុខនេះ ។

**២- <u>មតិឯកឧត្តម សៀង ប្ញទ្ធីស័ក្តិ តំណាងគណបក្ស ហ្វ៊ុន ស៊ិនប៉ិច</u> :**

គណបក្សហ្វ៊ុន ស៊ិនប៉ិច កំពុងធ្វើការយ៉ាងជិតស្និតជាមួយគណបក្សប្រជាជន ក្រោមការដឹកនាំរបស់សម្តេចក្រុមព្រះ

នរោត្តម រណឫទ្ធិ និង ឯកឧត្តម ញឹក ប៊ុនឆៃ ជាអគ្គលេខាធិការគណបក្ស ចូលរួមគាំទ្រស្របតាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ផែនការគោលដៅយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និង យុទ្ធសាស្ត្រចតុកោណ ដែលទាមទារអោយស្ត្រីចូល រួមក្នុងការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធិភាព និង មានចីរភាពយូរអង្វែង ។ ជាក់ស្តែងក្នុងអាណត្តិទី ០១ ទី ០២ និងទី ០៣ នេះគណបក្ស ហ្វ៊ុន ស៊ិនប៉ិច មានថ្នាក់ដឹកនាំស្ត្រីជាសមាជិករដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និង សមាជិកក្រុមប្រឹក្សា ឃុំ- សង្កាត់ជាច្រើនរូប ។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ មានស្ត្រីចូលរួមតែ ១៦% ហើយជាលទ្ធផលមានស្ត្រីតែ ៩% ប៉ុណ្ណោះដែលបានជាប់ឆ្នោត ។ ២/៣ នៃសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ នៅប្រទេសកម្ពុជាមិនមានតំណាង ស្ត្រីគ្រប់គ្រាន់នៅឡើយទេ ។ ការជួយជ្រោមជ្រែងពីគណបក្សនយោបាយ និង មេដឹកនាំ មិនទាន់គ្រប់គ្រាន់នៅឡើយ

ពោលគឺស្ត្រីត្រូវខិតខំប្រឹងប្រែងនិងប្តេជ្ញាចិត្តដោយខ្លួនឯងផង និង មានការជួយគាំទ្រពីស្ត្រីគ្នាឯងផង ទើបអាចជួយស្ត្រីសំរេច ដល់គោល ដៅដែលយើងទាំងអស់ គ្នាចង់បាន។ គណបក្សហ៊្វុនស៊ិនប៉ិចសូមគាំទ្រអនុសាសន៏របស់គណៈកម្មាធិការលើកស្ទួយ ស្ត្រីក្នុងវិស័យនយោបាយ ដែលបានស្នើសុំបង្កើនសមាមាត្រស្ត្រី ។

**៣- ឧត្តមលោកជំទាវ ម្ធូរ សុខហួរ តំណាងគណបក្ស សមរង្ស៊ី**

នៅពេលថ្មី១នេះ ប្រជាពលរដ្ឋខ្មែរកំពុងតែចុលរួមយ៉ាងសកម្មក្នុងការចុះឈ្មោះបោះឆ្នោត និង ទៅពិនិត្យមើលបញ្ជី ឈ្មោះបោះឆ្នោត គណបក្ស សមរង្ស៊ីក៏កំពុងតែត្រៀមខ្លួនចូលរួមបោះឆ្នោតឆ្នាំ២០០៧-២០០៨ ខាងមុខនេះ ។ ស្ត្រីមានសិទ្ធិ ក្នុងការចូលរួមធ្វើសេចក្តីសំរេចចិត្ត បើមានស្ត្រីចូលរួមក្នុងនយោបាយស្ត្រី អាចធ្វើអោយមានការកាត់បន្ថយអំពើពុករលួយ ។ លោកជំទាវ ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងកិច្ចការនារីដែលបានជួយដោះស្រាយបញ្ហាស្ត្រីដូចជាអំពើហឹង្សា ជាដើម ។ បច្ចុប្បន្នគណបក្សសមរង្ស៊ីកំពុងតែខិតខំជំរុញស្ត្រីអោយបានច្រើននៅក្នុងក្រុមប្រឹក្សាឃុំ-សង្កាត់ ។

ជាកិច្ចបន្តគឺជាការចាក់ផ្សាយខ្លឹមសាររបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានបង្ហាញពីការយកចិត្តទុកដាក់ របស់រាជរដ្ឋាភិបាលចំពោះស្ត្រី **"ស្ត្រីជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច និង សង្គមជាតិយើង"** ហើយធានាសិទ្ធិរបស់ស្ត្រី ចូលរួមយ៉ាងសកម្ម និង ស្មើភាពក្នុងការកសាងជាតិ ។

**៤- ឧត្តមឯកឧត្តម វ៉ាន់ ចំរើន តំណាងក្រសួងមហាផ្ទៃ**

តួនាទីរបស់ស្ត្រីជាប្រធានបទមួយដែលត្រូវយកចិត្តទុកដាក់។ កំណែទម្រង់ទុនសង្គម និងទុននយោបាយ មានន័យថា:

- ទុនសង្គមគឺជាទំនាក់ទំនងកិច្ចសហប្រតិបត្តិការប្រជាជន និង ប្រជាជន
- ទុនសង្គម គឺជាទំនាក់ទំនងកិច្ចសហប្រតិបត្តិការប្រជាជន និង ស្ថាប័ន

ឆ្លងតាមការបោះឆ្នោតក្រុមប្រឹក្សា ឃុំ-សង្កាត់ កន្លងមកយើងសង្កេតឃើញថាមានស្ត្រីចូលរួមក្នុងឆាកនយោបាយ តិចតួចណាស់ព្រោះមានការលំបាកក្នុងការរកស្ត្រីអោយចូលរួម គឺគាត់មិនចង់ធ្វើតែម្តងទោះបីជាទៅអង្វរគាត់ដល់ផ្ទះក៏ដោយ។ បច្ចុប្បន្នក្រសួងមហាផ្ទៃបាន បញ្ចប់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ចាប់ពីថ្នាក់ខេត្តដល់មូលដ្ឋាន ។

ក្នុងការកំណែទម្រង់លើទុនសង្គម និងទុនយោបាយត្រូវដំណើរការលើមូលដ្ឋានគ្រឹះវិសមភាពនៃយេនឌ័រដែលត្រូវយក ចិត្តទុកដាក់ចំពោះស្ត្រី ។ គោលដៅសំខាន់ៗមាន ៥ គឺ :

១-ការបោះឆ្នោតដោយផ្ទាល់ និង មិនផ្ទាល់

២-ការចូលរួមជាសាធារណៈ

៣- ការឆ្លើយតប និង តំរូវការជាក់ស្តែង

៤- គណនេយ្យភាព

៥- ដំនើរការគោរពច្បាប់ធម្មនុញ្ញ

## កម្មវិធី សំនួរ-ចម្លើយ

**សំណួរ :**

១- លោកស្រី ប្រុកវ៉ាន់នី មកពីអង្គការយូនិហ្វែម

លោកស្រីមានចំណាប់អារម្មណ៍ចំពោះប្រសាសន៏ឯកឧត្តម ង៉ាន់ ចំរើន ដែលថាពិបាកជ្រើសរើសស្ត្រីក្នុងការឈរឈ្មោះ បោះឆ្នោត ប្រសិនបើមានការលំបាកយ៉ាងនេះ តើលោកមានយុទ្ធសាស្ត្រអ្វីធ្វើអោយប្រសើរជាងនេះដែរឬទេ ?

២- លោក រាជ យឿន មកពីគណបក្សសមរង្ស៊ី

ឆ្លងតាមការបណ្តុះបណ្តាលស្ត្រីកន្លងមក លោកសង្កេតឃើញថាស្ត្រីគ្មានចេះអ្វីក្រៅពីការ ភ័យ ខ្លាច និង យំ

- តើគោលការណ៏ក្នុងការជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់យ៉ាងណា ?

- តើលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយដូចម្តេច បើភាពក្រីក្រចេះតែគ្របដណ្តប់លើស្ត្រី ក្នុងការបញ្ចេញមតិយោបល់ ពីព្រោះថាស្ត្រីចេះតែ ភ័យ, ខ្លាច និង យំ សូម្បីតែនៅក្នុងរដ្ឋសភាក៏មិនហ៊ានបញ្ចេញមតិយោបល់ដែរ ?

៣- លោកចៅ វ៉ាសនា មកពីអង្គការ IRI

ខ្ញុំឮអស់ពេលរយៈ ៥ឆ្នាំហើយ មានអង្គការមួយបាននិយាយថាស្ត្រីមិនចេះអក្សរនៅប្រទេសកម្ពុជាមានរហូតដល់ ៨0% តើមានគោលការអ្វីខ្លះក្នុងការជំរុញស្ត្រីអោយចូលរួមក្នុងឆាកនយោបាយ ?

**ចម្លើយ :**

១- ឯកឧត្តម ង៉ាន់ ចំរើន :

ចំពោះសំណួរនេះគឺបង្កើតអោយមានការងឿងឆ្ងល់យ៉ាងច្រើន ប៉ុន្តែសំរាប់គណបក្សនយោបាយនិមួយៗមានការយក ចិត្តទុកដាក់ណាស់ក្នុងការជ្រើសរើសនារីអោយចូលរួមបានច្រើន ប៉ុន្តែ វាពិបាកណាស់ក្នុងការជ្រើសរើសបេក្ខនារីអោយឈរ ឈ្មោះ ពីព្រោះថាគាត់មិនចង់ធ្វើ ជាក់ស្តែងលោកជំទាវ ហូ ណួន បានជំរាបហើយថាដល់ពេលជិតបោះឆ្នោតហើយគាត់ថាគាត់ មិនឈរឈ្មោះវិញ ត្រង់នេះហើយដែលជាការលំបាក ។

២- លោកជំទាវ ហូ ណួនៈ

- ភាពក្រីក្រ គ្របដណ្តប់នៅកម្ពុជា

- ការភ័យខ្លាចរបស់ស្ត្រីក្នុងការចូលរួមក្នុងឆាកនយោបាយ

ជាការពិតណាស់យើងទទួលស្គាល់ថាប្រទេសយើងបានឆ្លងកាត់សង្គ្រាមរ៉ៃងអន្លាយ ប៉ុន្តែយើងមិនគួរចោទតែទៅលើ សង្គ្រាមមួយមុខទេ ប្រទេសកម្ពុជាយើងកំពុងតែលើកស្ទួយស្ត្រីខ្លាំងណាស់

បើប្រៀបធៀបទៅនឹងប្រទេសផ្សេងៗទៀតគឺ យើងមានការរីកចំរើន ការកែប្រែតិរិយាបទសង្គម និង ភាពក្រីក្រ គឺជារបាំង ចំពោះការបណ្តុះបណ្តាលគឺជាចំនុចអាទិភាព ។

ចំពោះបញ្ហាភ័យខ្លាចគឺមានដោយកន្លែង ដូច្នេះមិនគួរមើលតែមួយជ្រុងនោះទេ ដូចពាក្យចាស់លោកបានពោលថា ដាំចង្រ្កានត្រូវប្រមាណឆ្នាំង មើលដើមឈើសូមកុំមើលតែមួយដើម ហើយកង្វល់នេះគឺជាកង្វល់យើងទាំងអស់គ្នា ភាពក្រីក្រ គឺជាសត្រូវរបស់យើង ដូច្នេះគួរបុរសជាស្វាមីទាំងអស់ត្រូវបង្កលក្ខណៈអោយភរិយាចូលរួមក្នុងឆាកនយោបាយអោយបាន ច្រើន។ ចំពោះការភ័យខ្លាចនៅសភាយើងដឹងហើយថា នៅសភាមានរដ្ឋធម្មនុញ្ញក៏បានចែងអំពីអភ័យឯកសិទ្ធិរបស់សភា ដូច្នេះកុំធ្វើអ្វីអោយប៉ះពាល់ដល់ស្ថេរភាពនយោបាយ និង កុំប៉ះពាល់ដល់សិទ្ធិអ្នកដ៏ទៃ ។

៣- <u>លោកជំទាវ មួរ សុខហួរ</u> :

យើងដឹងហើយថាការងារក្រុមប្រឹក្សាឃុំ-សង្កាត់ច្រើនណាស់។ ខ្ញុំបានសំណូមពរទៅរដ្ឋាភិបាល និង សភាសុំអោយ មានការបោះឆ្នោតសកលក្នុងការបោះឆ្នោតភូមិ តែក្រសួងមហាផ្ទៃបានណែនាំអោយបោះឆ្នោតជាអសកល។ ខ្ញុំចង់អោយ មានការបោះឆ្នោតជាឯកត្តនាម ព្រោះថាមានស្ត្រីច្រើនណាស់កំពុងធ្វើការងារតាមអត្រាអភិវឌ្ឍន៏នៅមូលដ្ឋាន។

៤- <u>ឯកឧត្តម សឿង ឫទ្ធីសក្ត</u> :

ចំពោះបញ្ហាស្ត្រីមិនចេះអក្សរមានរហូតដល់ ៨០ %នោះខ្ញុំមិនជឿទេ នេះជាតួលេខមិនជាក់ស្តែង ខ្ញុំបានគិតថាមាន

ស្ត្រីប្រហែល ៥០%ប៉ុណ្ណោះដែលមិនចេះអក្សរ ។ ប្រសិនបើចង់ជួយស្ត្រីអោយចូលរួមក្នុងឆាកនយោបាយ យើងឃើញថាមាន

ស្ត្រី ៣០% អាចប្រើការបាន ដូច្នេះសុំអោយគណបក្សនិមួយៗ កុំប្រកាន់ពេកគឺត្រូវជួយគាត់ ប្រសិនបើយើងយកអ្នកមិនចេះ អក្សរមកធ្វើការវាក៏ពិបាកដែរ គាត់មិនចេះទំនាក់ទំនងទាំងការងារទូទៅ និង ការងារផ្ទាល់ខ្លួន ដូច្នេះយើងត្រូវយកអ្នកចេះ អក្សរមកជួយយើងព្រោះការងារឃុំ-សង្កាត់មានច្រើនណាស់។ ត្រង់បញ្ហានេះយើងពឹងផ្អែកតែលើគណបក្សមួយមុខក៏មិន កើតដែរ ។

**<u>សំណួរ</u>** :

១- <u>លោក ពុទ្ធា រិទ្ធ មកពីអង្គការ KID</u>

តើក្នុងគោលវិស័យ និង យន្តការណាខ្លះដើម្បីអោយស្ត្រីចូលរួមក្នុងវិស័យនយោបាយ និងជួយគ្នាទៅវិញទៅមក។ ពីព្រោះថាស្ត្រីចេះ ភ័យ, ខ្លាច និងយំ។ តើមានយន្តការណាខ្លះដើម្បីអោយស្ត្រីបាត់ចំណុចទាំង ៣នេះ គឺ ភ័យ, ខ្លាច និង យំ ?

**<u>ចំលើយ</u>** :

១- <u>លោកជំទាវ ឃឹម ចំរើន</u> :

បើនិយាយពីគោលនយោបាយ យើងចង់ជំរុញស្ត្រីអោយចូលរួមបានច្រើនតាំងពីបោះឆ្នោតលើកមុន ប៉ុន្តែមកដល់ឥឡូវនេះស្ត្រីនៅតែតិច។ ចរិករបស់ស្ត្រី គឺមានភាពទន់ខ្សោយ ឆាប់ភ័យខ្លាច និង យំ ជាការពិត។ ក្រសួងកិច្ចបានសហការយ៉ាងជិតស្និតជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីលើកស្ទួយស្ត្រី ខ្ញុំបានលើកឡើងថា មូលហេតុអ្វីបានជាស្ត្រីមិនចង់ចូលរួម គឺគាត់ខ្លាចប្តីរបស់គាត់បែកចិត្ត ការងារផ្ទះសម្បែង,ប្រាក់បៀវត្សតិច។

ការរៀបចំវេទិកាសារធារណៈរបស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ បានធ្វើអោយស្ត្រីក្លាហានមានការយល់ដឹង ចេះប្រឈមមុខនិងដោះស្រាយបញ្ហា ។ ការបោះឆ្នោតគឺជាប្រព័ន្ធបោះឆ្នោតសមាមាត្រ ដូច្នេះគណបក្សនយោបាយទាំងអស់ត្រូវយកចិត្តទុកដាក់ យើងទាំងអស់ត្រូវសហការគ្នាជាពិសេសបុរស ហើយកត្តាបៀវត្សក៏ជាកត្តាសំខាន់ ណាស់ដែរ។ តាមគោលគំនិតខ្ញុំបានគិតថា សុំអោយមានការបោះឆ្នោតជ្រើសរើសស្ត្រីជាតំណាងជាមុនសិន ប៉ុន្តែក្រសួង មហាផ្ទៃមិនឯកភាព។ បច្ចុប្បន្នក្រសួងបានបញ្ច្រាបយេនឌ័រនៅក្នុងគោលនយោបាយវិមជ្ឈការ។ ដូច្នេះយើងត្រូវជំរុញស្ត្រីវ័យ ក្មេងៗ (បញ្ចប់បាក់ឌុប) អោយឈរឈ្មោះបោះឆ្នោត ។

២- <u>លោកស្រី ធីតា យឹះ :</u>

ឧបសគ្គរាំងមិនអោយស្ត្រីឈរឈ្មោះគឺមកពីកត្តា ២ គឺកត្តាបុគ្គល និងកត្តាប្រព័ន្ធ អ្នកប្រាជ្ញាបាននិយាយថា បញ្ហាគឺជា ឱកាស។ ការភ័យ ខ្លាច យំ របស់ស្ត្រីមិនមែនជាបញ្ហាទេ គឺគាត់បានបង្ហាញភាពស្មោះត្រង់ នេះគឺជាតួនាទីរបស់យើងទាំងអស់ គ្នា យើងគួរតែចាប់ផ្តើមធ្វើពីពេលនេះតទៅ ហើយក្នុងការធ្វើនេះមិនដើម្បីអំណាចទេ ។ កន្លងមកយើងបានបើកវគ្គបណ្តុះ បណ្តាលដល់ស្ត្រី ដើម្បីអោយគាត់បាត់ភ័យ ខ្លាច ហើយមានការយល់ដឹង ក្លាហាន ចេះប្រឈមមុខ និងដោះស្រាយបញ្ហា ផ្សេងៗ ។

**<u>សំណួរ</u> :**

- <u>លោកជំទាវ មួរ សុខហួរ តំណាងគណៈបក្សសមរង្ស៊ី</u> :

តើ គណៈក្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ និងតស៊ូមតិដោយវិធីណាដើម្បីជំរុញស្ត្រីអោយចូលរួមកាន់តែ ច្រើន ?

**<u>ចំលើយ :</u>**

១- <u>លោកស្រី ប៉ុក ណណ្ណា</u> :

ពីដើមយើងមានអង្គការតិចតួចណាស់ ធ្វើការងារស្ត្រីចូលរួមក្នុងវិស័យនយោបាយ។ យើងបានបង្កើតសហគមន៍អង្គការសមាគមលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ដើម្បីធ្វើការងារនេះដោយធ្វើការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងតាម ដានគណៈបក្សនយោបាយ ដែលបានសន្យា តើធ្វើបានដល់កំរិតណា។ ចំពោះបញ្ហានយោបាយមិនមែនងាយស្រួលទេ ដូច្នេះយើងបានប្តេជ្ញាចិត្តថានឹងធ្វើការនេះយ៉ាងប្តូរផ្តាច់ដោយមិនរាថយ និងសូមអោយមានការគាំទ្រពីគ្រប់ស្ថាប័ន និងគណ បក្ស នយោបាយ ទាំងបី ។

២- <u>លោកជំទាវ ហូ ណួន</u> :

នៅកម្ពុជាអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស។ បើចង់បានយ៉ាងណា ទាល់តែគណៈបក្សទាំង ៣ឯកភាពគ្នា។ នៅកម្ពុជាទាក់ទងនិង លំហ ឱកាស ការចូលរួម។

៣- លោកស្រី ធីតា ឃី :

សកម្មភាពដែលមានកន្លងមកគ្រាន់តែជាការចាប់ផ្តើមទេ

គណៈកម្មាធិការយើងមានបំណងបង្កើតវិទ្យាស្ថាននយោ- បាយមួយសំរាប់ស្ត្រី។

កម្មវិធីបើកសម្ពោធ

កម្មវិធីរបស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយជាផ្លូវការបានបញ្ចប់នៅវេលា ម៉ោង ១៧,២០នាទី ក្រោមបរិយាកាសសប្បាយរីករាយ និង ស្និតស្នាល ។

## កម្មវិធីសន្និសិទកាសែត

នៅវេលាម៉ោង ១៧,២៥នាទី គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ បានប្រារព្ធពិធីសន្និសិទកាសែត ដោយមានបណ្តាញពតិមាន កាសែត វិទ្យុ និង ទូរទស្សន៍ជាច្រើនបានចូលរួម ខ្លឹមសារមានដូចខាងក្រោម :

វាគ្មិន : សមាជិកគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយទាំង ៧ អង្គការ

ជាកិច្ចចាប់ផ្តើមលោកស្រី ប៉ុ ណណ្ណ នាយិកាអង្គការចំរើនស្ត្រី បានឡើងរាយការណ៍ពីកម្មភាពការងារ របស់គណៈ កម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ :

១- ធ្វើការបញ្ចុះបញ្ចូល និង តស៊ូមតិ

២- បើកវគ្គបណ្តុះបណ្តាលដល់ បេក្ខនារីឃុំ-

សង្កាត់កន្លងមកអង្គការរបស់លោកស្រីបានធ្វើការបណ្តុះបណ្តាលបេក្ខនារី

ឃុំ-សង្កាត់ បានចំនួន ១១ខេត្ត-ក្រុង គឺសៀមរាប បាត់ដំបង កំពង់ចាម កំពង់ធំ ក្រចេះ ប៉ៃលិន កំពត តាកែវ រាជធានីភ្នំពេញ

កណ្តាល និង ក្រុងកែប ។

៣-តស៊ូមតិទៅគណបក្សនយោបាយដើម្បីអោយគាត់ដាក់បេក្ខនារីនៅជួរខាងលើ (ស្ត្រី១នាក់ក្នុងចំណោម៣) ធ្វើ ដូចនេះស្ត្រីនិងមានវាសនាជាប់ឆ្នោត ។

៤- រៀបចំវេទិកាសាធារណៈក្រោមប្រធានបទ សុខុមាលភាពសង្គម និង ស្ត្រីក្នុងការសំរេចចិត្ត ដែលបានជួយឧបត្ថម្ភ ថវិកាដោយ UNDP UNFP GTZ World Bank ។

គណៈកម្មាធិការមានមហិច្ឆិតាមួយគឺ ដើម្បីអោយស្ត្រីឈរឈ្មោះបោះឆ្នោត និង ចូលរួមក្នុងឆាកនយោបាយ ។

ជាកិច្ចបន្តលោកហង្ស ពុទ្ធា ប្រធានអង្គការនិកហ្វិក បានឡើងរាយការណ៍ពីកសម្មភាពការងារថា : លោកធ្វើសកម្មភាពផ្សព្វផ្សាយតាមបែបសិល្បៈ ពីព្រោះប្រជាពលរដ្ឋសព្វថ្ងៃនេះគាត់និយមចូលចិត្តផ្នែកសិល្បៈ

អង្គការរបស់ លោកបានបង្កើតជារឿងមួយដែលមានឈ្មោះថា សំណាបយោងដីស្ត្រីយោងបុរស នេះជាវិធីសាស្ត្រមួយដែលធ្វើអោយស្ត្រី ចូករួមក្នុងវិស័យនយោបាយ ។

ជាកិច្ចបន្តលោកស្រី អ៊ុក សុធារ៉ា បានឡើងរាយការណ៍ពីសកម្មភាពការងារដែលបានអនុវត្តកន្លងមកថា កន្លងមក អង្គការរបស់លោកស្រីបានរៀបចំវេទិកាសាធារណៈចំនួន ២ ខេត្តរួចមកហើយ គឺខេត្តកំពង់ធំ និង ខេត្តកំពត យើងនឹងបន្តទៅ ខេត្តសៀមរាប បាត់ដំបង កំពង់ចាម និង ប៉ៃលិន ដោយទទួលបានប្រាក់ឧបត្ថម្ភពី UNFP GTZ ។ ក្នុងកិច្ចដំណើការយើង បានធ្វើនៅក្នុងស្រុក ១ មាន ៣ ឃុំ និង ផ្តល់ឱកាសអោយអ្នកចូលរួមចំនួន ១០០ នាក់ វាគ្មិននៅថ្នាក់មូលដ្ឋានមាន មេស្រុក មេឃុំ តំណាងឃុំជាស្ត្រី និង បុរស អង្គការដៃគូនៅមូលដ្ឋាន ។

ពេលព្រឹកយើងមានកម្មវិធីសំណួរ-ចម្លើយ ដោយអោយប្រជាពលរដ្ឋធ្វើការសាកសួរដល់វាគ្មិនអំពីការឈរឈ្មោះបោះ ឆ្នោត និង ចែកក្រុមពិភាក្សាផ្តោតជាសំខាន់អំពីតួនាទីរបស់បុរស និង ស្ត្រីដែលមិនអាចខ្វះបាន ។

ពេលល្ងាច : កម្មវិធីសំនួរ-ចម្លើយយករង្វាន់ និង ការសំដែងតួរបស់ប្អូនៗយុវជនមួយក្រុមដែលមានចំណងជើងថា : មេឃុំស្ត្រី រឿងនេះទាក់ទងទៅនឹងស្ត្រីឈរឈ្មោះបោះឆ្នោត ដោយមានប្រជាពលរដ្ឋជាច្រើនចូលរួម ព្រមទាំងមានអង្គការ GTZ DOLA CWPD ។

ជាកិច្ចបន្តកញ្ញា សឹន សុកេតស្រីល័ក្ខ បានឡើងរាយការណ៍ពីសកម្មភាពការងារដែលបានអនុវត្តកន្លងមកថា គំរោង UNDF ផ្តោតសំខាន់លើការបណ្តុះបណ្តាលបេក្ខនារីជាស្ត្រីរហូតដល់ជាប់ឆ្នោត បង្កើតបណ្តាញនៅតាមឃុំ-សង្កាត់ ដោយ ជ្រើសរើសបណ្តាញ ២នាក់មកបណ្តុះបណ្តាលក្នុងគោលបំណង :

១- ជួយដល់ស្ត្រីដែលមានបំណងឈរឈ្មោះបោះឆ្នោត

២- បណ្តាញធ្វើសកម្មភាពមុន និង ក្រោយបោះឆ្នោត

៣- ជួយដល់ស្ត្រីដែលជាប់ឆ្នោត

## កម្មវិធីសំណួរ :

**សំណួរ :**

១- ទូរទស្សន៍ បានសួរទៅលោកហង់ ពុទ្ធា

តើលោកមានកម្មវិធីអ្វីជាមួយគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ? ពីព្រោះកន្លងមកលោកធ្វើការ អប់រំ ផ្សព្វផ្សាយពេលបោះឆ្នោត និងចន្លោះពេលបោះឆ្នោត ។

**ចម្លើយ :**

និកហ្វិកធ្វើការអប់រំទាក់ទងទៅនឹងសិល្បៈ ហើយសកម្មភាពនេះក៏ទាក់ទងទៅនឹងស្ត្រីដែរ ហើយរូបខ្ញុំផ្ទាល់ក៏ជាសមា

ជិករបស់គណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ដូច្នេះយើងធ្វើការងាររួមគ្នាក្នុងការលើកស្ទួយស្ត្រី គោលបំណង តែមួយគត់គឺ អោយស្ត្រីចូលរួមក្នុងការឈរឈ្មោះបោះឆ្នោត ។

**សំណួរ** :

- តើធ្វើដូចម្តេចដើម្បីអោយស្ត្រីឈរនៅលំដាប់លេខ ១ សួរខាងខុមហ្វ្រែល

**ចម្លើយ** :

១- សឹន សុកេតស្រីល័ក្ខ :

ជាការពិតសង្គមស៊ីវិលគឺធ្វើយ៉ាងណាដើម្បីអោយស្ត្រីជាប់ឆ្នោត

កន្លងមកយើងបានធ្វើយុទ្ធនាការមួយដើម្បីអោយ

ស្ត្រីឈរឈ្មោះនៅលំដាប់លេខ ១ ជាលទ្ធផលយើងពិបាកក្នុងការធ្វើយ៉ាងណាអោយស្ត្រីបានឈរនៅលំដាប់លេខ ១ យើងបាន សំណូមពរសុំអោយមានការឆ្លាស់គ្នាក្នុងការដោកឈ្មោះក្នុងបញ្ជី ធ្វើយ៉ាងនេះយើងសង្ឃឹមថានឹងមានស្ត្រី ២៥% ជាប់ឆ្នោត ។

២- លោកស្រី ប៉ុក ណណ្ណា :

បទពិសោធន៏ការបោះឆ្នោតឆ្នាំ ២០០១ មានស្ត្រី១០០០នាក់ជាប់ឆ្នោត ផ្ទុយពីមុនដែលមានចំនួនតិចតួច ប៉ុន្តែពេល នេះអាស្រ័យទៅលើគណបក្សនយោបាយនិមួយៗ តើគាត់គោរពពាក្យសន្យាដែរឬទេ ?

**សំណួរ** : លោក សុខ ជា មកពីទួរទស្សន៍បាយ័ន

មានមេឃុំ មេភូមិមួយចំនួនមានការរារែកក្រោយពេលជាប់ឆ្នោត ?

**ចម្លើយ** :

១- សឹន សុកេតស្រីល័ក្ខ :

- ការបង្កើតបណ្តាញនៅតាមភូមិ ឃុំ គឺជួយពង្រឹងសមត្ថភាព និង តួនាទីភារកិច្ច របស់ស្ត្រី

- តាមដានការរំលោភសិទ្ធនិង តួនាទីភារកិច្ចលើបុរសចំពោះស្ត្រី

២- លោកស្រី ធីតាឃីះ :

- យើងធ្វើនេះវាខុសប្លែកជាងពេលមុន កន្លងមកគណបក្សនយោបាយមិនធ្វើ

តែពេលនេះយើងធ្វើការតស៊ូមតិដើម្បី

អោយមេឃុំជាស្ត្រីឈរលេខរៀងទី១ ទាំងមុននិងក្រោយការបោះឆ្នោត ។

- ចុះធ្វើការតស៊ូមតិតាមខេត្ត ស្រុក ឃុំ

- ចុះជួបមេបក្សទាំង៣ សុំអោយ៣នាក់ជួរខាងលើមានស្ត្រី ១នាក់

- ធ្វើអោយអ្នកបោះឆ្នោតយល់ថាស្ត្រីគួរត្រូវបានគាំទ្រ  ដូច្នេះសុំអោយអ្នកការសែត ទូរទស្សន៍ជួយផ្សព្វផ្សាយផង។

៣- លោក ហង់ ពុទ្ធា សុំអោយនៅក្នុងការិយាល័យបោះឆ្នោត ៦នាក់ យ៉ាងហោចណាស់មានស្ត្រី ១នាក់នៅក្នុងការិយាល័យ ។

៤-លោកស្រី អ៊ុក សុធារ៉ា តាមបទពិសោធន៍រៀបចំវេទិកាសាធារណៈកន្លងមក យើងធ្វើការចែកក្រុមពិភាក្សាដោយ អោយអ្នកចូលរួមធ្វើការប្រៀបធៀបរវាងឃុំ-សង្កាត់ដែលមានតែបុរស និង ឃុំ-សង្កាត់ដែលមានតែស្ត្រី និង ឃុំ-សង្កាត់ដែល មានបុរសផង និង ស្ត្រីផង  ជាលទ្ធផលយើងសង្ឃឹមថានិងមានស្ត្រី ១៥ភាគរយចូលរួម ។

នៅទីបញ្ចប់លោកស្រី ធីតាឃីះ បានថ្លែងអំណរគុណចំពោះបណ្តាអ្នកកាសែត និងទូរទស្សន៍ទាំងអស់ដែលបានចំណាយ ពេលវេលាចូលរួមធ្វើសន្និសិទការសែតនេះ ។

សន្និសិទកាសែតបានបញ្ចប់នៅវេលាម៉ោង ១៨,៤០នាទី ក្រោមបរិយាកាសសប្បាយរីករាយ និង ស្និតស្នាល  ។

ភ្នំពេញ, ថ្ងៃទី            ខែ តុលា ឆ្នាំ ២០០៦

អ្នកធ្វើកំណត់ហេតុ

អៀង សុភក្ត្រ័